ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សារលិខិតអបអរសាទរ

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

***សម្តេចតេជោនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

នាឱកាសដ៏មហានក្ខត្តឫក្សវិសេសវិសាល និងជាមហាកិត្តិយសដ៏ឧត្តុង្គឧត្តមបំផុតដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានទទួលពានរង្វាន់ **“*សមិទ្ធផលអមតៈអាស៊ាន*”** (**ASEAN Lifetime Achievement Award**) **ពីវិទ្យាស្ថានយុទ្ធសាស្ត្រ និងភាពជាអ្នកដឹកនាំអាស៊ី** (**Asian Strategy & Leadership Institute-ASLI**) **នៅទីក្រុងវៀងច័ន្ទ នៃសាធារណរដ្ឋប្រជាមានិតឡាវ** តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង និងសូមសម្តែងនូវអំណរសាទរប្រកបដោយក្តីរំភើបរីករាយជាទីបំផុតជាមួយនឹងមនោសញ្ចេតនាគោរពកោតសរសើរយ៉ាងជ្រាលជ្រៅជូនចំពោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលនេះមិនត្រឹមតែជាមហាកិត្តិយសដ៏ឧត្តុង្គឧត្តមថ្លៃថ្លារបស់សម្តេច និងក្រុមគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាមោទកភាពរបស់ប្រជាជន និងប្រជាជាតិខ្មែរថែមទៀតផង។

ពានរង្វាន់ **“*សមិទ្ធផលអមតៈអាស៊ាន*”** (**ASEAN Lifetime Achievement Award**) បានប្រគល់ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** នាពេលនេះគឺពិតជាស័ក្តិសមបំផុតចំពោះគំរូវីរភាព និងគុណបំណាច់ដ៏ថ្លៃថ្លារបស់សម្តេចក្នុងនាមជាអគ្គមគ្គុទេសក៍ដ៏ឆ្នើមក្នុងការដឹកនាំតស៊ូរំដោះប្រទេសជាតិឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ និងបានខិតខំពុះពារកសាងសុខសន្តិភាព កសាងខឿនការពារជាតិការពារបូរណភាពទឹកដីកម្ពុជាប្រកបដោយភាពឈ្លាសវៃ និងគតិបណ្ឌិតតាមរយៈការអនុវត្ត **គោលនយោបាយ “ឈ្នះ-ឈ្នះ”** ដែលជាទស្សនវិជ្ជាដឹកនាំដ៏ខ្ពង់ខ្ពស់ក្នុងការប្រែក្លាយប្រទេសកម្ពុជាពីប្រទេសដែលមានសង្គ្រាមរ៉ាំរ៉ៃមក ជាប្រទេសដែលមានសន្តិភាពគ្របដណ្តប់ពាសពេញផ្ទៃប្រទេស និងមានការអភិវឌ្ឍយ៉ាងលឿនប្រកបដោយវិបុលភាពលើគ្រប់វិស័យ ធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាទទួលបាននូវកិត្តិស័ព្ទល្បីរន្ទឺទាំងក្នុងតំបន់ និងអន្តរជាតិ។

យើងខ្ញុំទាំងអស់គ្នា ពិតជាមានមោទកភាពជាទីបំផុត និងសូមយកឱកាសដ៏មហាប្រសើរថ្លៃថ្លានេះបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមជួយប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការជូនដល់ **សម្តេចតេជោនាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងក្រុមគ្រួសារ** សូមបានសមប្រកបនូវសុខភាពល្អបរិបូរណ៍ អាយុយឺនយូរ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បីដឹកនាំ និងអភិវឌ្ឍមាតុភូមិកម្ពុជាក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមបម្រើជាតិ និងប្រជាជនកម្ពុជាឱ្យកាន់តែ រីកចម្រើនឈានឆ្ពោះទៅរកភាពរុងរឿងសំបូរសប្បាយជានិច្ចនិរន្តរ៍។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវភក្តីដ៏ស្មោះស្ម័គ្រ និងអភិវន្ទន៍កិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។ ៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ សីហា ឆ្នាំ២០១៦

**តំណាងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**